00287001

E5/10/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 11 / MAR / 2009
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អវតក/អជសដ

**Case File/Dossier No. 001/18-07-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មុណី

កាលបរិច្ឆេទ: ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០០៩
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 11 / MAR / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

---

# សេចក្តីសម្រេចអំពីភាពអាចទទួលយកបាននៃភស្តុតាងថ្មី និងសេចក្តីណែនាំដល់សាក្សីទាំងអស់

---

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**ជនជាប់ចោទ**
កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE

ទី ស្រីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN

**មេធាវីជនជាប់ចោទ**
ការ សាវុត
François ROUX

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

E5/10/2

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អវតក”)។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-អវតក/អជសង តាម “សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនិង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច” ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ និងបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៨ (“សេចក្តីសម្រេច”)។

**ក្រោយពីបានទទួល** បញ្ជីឯកសារថ្មី និងសំណើសុំដាក់ភស្តុតាងថ្មីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩។

**ក្រោយពីបានពិចារណាលើ** សេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់របស់ភាគីក្នុងអំឡុងពេលសវនាការបឋមនៅថ្ងៃទី ១៧ និងទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩ ទាក់ទងនិងភាពអាចទទួលយកបាននូវភស្តុតាងថ្មី។

**អនុលោមតាម** វិធាន៣៩, ៨០, ៨៧ និង ៩២ នៃវិធានផ្ទៃក្នុង (“វិធាន”)។

## អង្គហេតុ និង សំអាងហេតុ

### ក. អំពីអង្គហេតុ

១. តាមដីកាចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨[1] អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីទាំងអស់អំពីការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ និងបង្គាប់ឱ្យភាគីទាំងអស់ដាក់បញ្ជីឯកសារថ្មីដែលភាគីមានបំណងដាក់នៅក្នុងសំណុំរឿងនៅពេលជាមួយគ្នានិងការដាក់បញ្ជីឈ្មោះសាក្សី ដូចដែលមានយោងក្នុងវិធាន៨០ នៃវិធានផ្ទៃក្នុង។

២. យោងតាមវិធាន៨០ កាលបរិច្ឆេទចុងក្រោយសម្រាប់សហព្រះរាជអាជ្ញាក្នុងការដាក់បញ្ជីឈ្មោះសាក្សីនិងភស្តុតាងបន្ថែមត្រូវផុតកំណត់ក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីដីកាបញ្ជូនរឿងទៅជំនុំជម្រះបានចូលជាធរមាននៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨ ។

អង្គជំនុំជម្រះសាលាដំបូង TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • E T C

[1] ឯកសារ E5

៣. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨[2] សហព្រះរាជអាជ្ញាបានដាក់សារណាតបរបស់ខ្លួនទៅនឹងដីការបស់អង្គជំនុំជម្រះសាលាដំបូងស្តីអំពីការដាក់ជូនភស្តុតាងបន្ថែម ដែលរួមមានបញ្ជីឯកសារថ្មី និងបានស្នើសុំសេចក្តីណែនាំពីអង្គជំនុំជម្រះពីរបៀបដាក់សំណៅឯកសារដើមជាភាសាខ្មែរ "ផែនការរួមចុងក្រោយ" (ឯកសារលេខ២៩)[3] នៅចំពោះមុខអង្គជំនុំជម្រះដើម្បីធ្វើការពិនិត្យ។ សហព្រះរាជអាជ្ញាបានបង្ហាញថា David Chandler ដែលនៅក្នុងសៀវភៅរបស់គាត់មានចំណងជើងថា *"សម្លេងចេញពីមន្ទីរ ស-២១[4]"* ធ្វើការកត់សម្គាល់ថា ឯកសារដើមជាភាសាខ្មែរត្រូវបានគេតម្កល់ទុកក្នុងបណ្ណាសារដ្ឋាន សារៈមន្ទីរទួលស្លែង និងបានថតចម្លងជាមីក្រូហ្វីលនៅសាកលវិទ្យាល័យ Cornell[5]។

៤. តាមសំណើសុំដាក់ជូនភស្តុតាងថ្មី ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩[6] សហព្រះរាជអាជ្ញាក៏បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យមានការដាក់ជូនភាពយន្តឯកសារនៃមន្ទីរ ស-២១ ដែលទើបត្រូវបានគេរកឃើញថ្មីៗនេះ និងស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ទទួលយកភាពយន្តនេះជាភស្តុតាងនៅពេលជំនុំជម្រះសំណុំរឿងនេះ។

៥. សហព្រះរាជអាជ្ញាបានឱ្យដឹងថា អត្ថិភាពនៃភាពយន្តឯកសារទាំងនេះបានដឹងជាសាធារណៈ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៨ នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រកាសប្រាប់ដល់សារព័ត៌មានថា ខ្លួនទទួលបានភាពយន្តឯកសារ។ ភាពយន្តឯកសារនោះត្រូវបានការិយាល័យសហព្រះរាជអាជ្ញាពិនិត្យមើលចាប់ពីថ្ងៃទី៦ ខែមករា ឆ្នាំ២០០៩។ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រគល់ភាពយន្តឯកសារថតចម្លងជូនដល់ការិយាល័យសហព្រះរាជអាជ្ញានៅថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩ តាមសំណើរបស់សហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាបានបង្ហាញអំពីវគ្គជាក់លាក់ពីរនៃភាពយន្តឯកសារទាំងនោះ ដែលខ្លួនគិតថាទាក់ទិនទៅនឹងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសង[7]។

**ខ. អំពីសំអាងហេតុ**

៦. ដើម្បីប្រកាសថាឯកសារថ្មីអាចទទួលយកបាន ឯកសារថ្មីនោះត្រូវតែ៖

---

[2] ឯកសារ E5/2

[3] ឯកសារ E5/2.29

[4] CHANDLER David *សម្លេងចេញពីមន្ទីរ ស-២១* ជើងទំព័រទី២៦ ទំព័រ១៦៨

[5] ឯកសារ E5/2 កថាខណ្ឌ១៤។

[6] ឯកសារ E5/10

[7] ERNs V00271181-V00271181 និង V002711821- V00271182

អង្គជំនុំជម្រះសាលាដំបូង TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

១. (ក) ដាក់ជូនមុនកាលបរិច្ឆេទណាមួយដែលបានកំណត់ដោយអង្គជំនុំជម្រះ ឬ កំណត់ដោយវិធានផ្ទៃក្នុង ឬ

(ខ) នៅពេលដែលករណីលើកលែងកើតមានឡើង ហើយអ្នកដាក់ពាក្យសុំបានស្វះស្វែងដាក់ឯកសារបន្ទាប់ពីការផុតរលត់នៃពេលវេលាកំណត់ អ្នកដាក់ពាក្យសុំនោះត្រូវបង្ហាញថាខ្លួនមិនមានលទ្ធភាពអនុវត្តតាមកាលបរិច្ឆេទនោះបានទេ និងត្រូវបង្ហាញទៀតថាភស្តុតាងនោះត្រូវបានដាក់ជូនក្នុងពេលមួយដែលអាចធ្វើបានដំបូងបំផុត។

២. ការវាយតម្លៃបឋមបង្ហាញនូវភាពពាក់ព័ន្ធទៅនិងការបញ្ជាក់ការពិត ប៉ុន្តែ ភស្តុតាងនេះនឹងត្រូវយកមកវាយតម្លៃ ក្នុងអំឡុងពេលសវនាការលើអង្គសេចក្តី។

៧. អនុលោមតាមវិធាន ៣៩(៤)(ខ) អង្គជំនុំជម្រះរក្សាសិទ្ធិទទួលយកឯកសារទាំងឡាយដែលស្ថិតនៅក្រោមប្រភេទលក្ខខណ្ឌខាងលើ ។ សំណើរបស់សហព្រះរាជអាជ្ញាទាក់ទងនិងឯកសារដែលមានចំណងជើងថា "ផែនការរួមចុងក្រោយ" ពិតជាបានដាក់តាមរយៈពេលខាងលើ ។ ទោះបីជា យថាភាពនៃឯកសារនេះនឹងត្រូវសម្រេចក៏ដោយ ការវាយតម្លៃបឋមនៃឯកសារនេះ ទំនងជាពាក់ព័ន្ធទៅនឹងការស្វែងរកការពិតចំពោះអង្គហេតុក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង ដូច្នេះឯកសារនេះអាចទទួលយកបាន។

៨. ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីជួយដល់អង្គជំនុំជម្រះក្នុងការសម្រេចអំពីយថាភាពនៃឯកសារនេះ អង្គជំនុំជម្រះចាំបាច់ត្រូវពិចារណាទៅលើភស្តុតាងទាំងអស់ដែលអាចមានការពាក់ព័ន្ធទៅនឹងបញ្ហានេះ ។ ប្រសិនបើសារៈមន្ទីរទួលស្លែងមានឯកសារដើមជាភាសាខ្មែរ ឬ សាកលវិទ្យាល័យCornell មានឯកសារថតចម្លងជាមីក្រូហ្វីល នៅពេលនោះអង្គជំនុំជម្រះផ្តល់សិទ្ធិឱ្យសហព្រះរាជអាជ្ញាស្វែងរកឯកសារទាំងនោះដាក់ជូនអង្គជំនុំជម្រះដោយមិនពន្យាពេលឡើយ ។ អង្គជំនុំជម្រះនឹងទទួលខុសត្រូវចំពោះការរក្សាសុវត្ថិភាពឯកសារទាំងនោះ ហើយឯកសារទាំងនោះក៏អាចផ្ទេរដោយផ្ទាល់ទៅអង្គជំនុំជម្រះតែម្តងក្នុងករណីសមស្រប ។ ម៉្យាងវិញទៀត សហព្រះរាជអាជ្ញាអាចកាន់កាប់ឯកសារទាំងនោះ ហើយដាក់ឯកសារទាំងនោះក្នុងសំណុំរឿងស្របតាមនីតិវិធីដែលបានកំណត់ ។ សហព្រះរាជអាជ្ញាត្រូវបានគេណែនាំឱ្យស្នើសុំភស្តុតាងទាំងនេះជាផ្លូវការពីសារៈមន្ទីរទួលស្លែង និង/ឬពីសាកលវិទ្យាល័យ Cornell។

៩. អង្គជំនុំជម្រះនឹងស្វែងរកកិច្ចសហប្រតិបត្តិការពីស្ថាប័នទាំងពីរនេះ ហើយនៅដំណាក់កាលនេះ អង្គជំនុំជម្រះនឹងមិនចេញដីកាណាមួយទៅដល់ស្ថាប័ននេះ ទាក់ទងនិងភស្តុតាងដែលត្រូវការនោះឡើយ។

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

១០. សហព្រះរាជអាជ្ញាមានពេលវេលារហូតដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ ដើម្បីអនុវត្តតាមសេចក្តីណែនាំនេះ។

១១. តាមរយៈមេធាវីរបស់គាត់ ជនជាប់ចោទបានបដិសេធថាមិនមានឯកសារដើម ឬមួយគាត់មិនបានសរសេរឯកសារនោះឡើយ។ ជនជាប់ចោទត្រូវតែបង្ហាញភស្តុតាងពីការលើកឡើងនេះ ហើយបន្ទាប់ពីអង្គជំនុំជម្រះ ឬសហព្រះរាជអាជ្ញាបានទទួលឯកសារខាងលើពីសារៈមន្ទីរទួលស្លែង ឬ ពីសាកលវិទ្យាល័យCornell គាត់នឹងមានឱកាសធ្វើចម្លើយតប។ ថិរវេលាកំណត់ជាក់លាក់មួយនឹងត្រូវកំណត់ នៅពេលដែលឯកសារនោះអាចរកបាន។

១២. ឥឡូវនេះ ការស្នើសុំទទួលយកនូវខ្សែភាពយន្តឯកសារទាំងពីរវគ្គនេះ គឺធ្វើឡើងក្នុងរយៈពេលផុតកំណត់ ។ ទោះបីជាយ៉ាងណាក៏ដោយ ផ្អែកតាមការអះអាងរបស់សហព្រះរាជអាជ្ញា ដែលថាសហព្រះរាជអាជ្ញាមិនបានដឹង និងមិនមានហេតុផលណាមួយដែលដឹងអំពីអត្ថិភាពនៃឯកសារនេះមុនថ្ងៃដែលឯកសារនេះត្រូវបានរកឃើញ ឬ ត្រូវបានបង្ហាញដោយមជ្ឈមណ្ឌលឯកសារកម្ពុជា អង្គជំនុំជម្រះទទួលស្គាល់ថាសហព្រះរាជអាជ្ញាមិនមានលទ្ធភាពទទួលបានខ្សែភាពយន្តឯកសារនេះ នៅក្នុងរយៈពេលដែលបានកំណត់ ឡើយ ។ ក្រោយមកខ្សែភាពយន្តនោះត្រូវបានដាក់ជូននៅពេលវេលាសមស្របដំបូងបំផុត ហើយការវាយតម្លៃបឋមបង្ហាញថា ខ្សែភាពយន្តនេះមានភាពពាក់ព័ន្ធ ។ លើសពីនេះទៀត មិនមានហេតុផលដែលបង្ហាញថា ការយឺតយ៉ាវក្នុងការដាក់ជូនភស្តុតាងធ្វើឡើងដោយចេតនានិងដើម្បីគេចពីដំណាក់កាលស៊ើបអង្កេតនោះឡើយ។

១៣. តាមរយៈមេធាវីរបស់គាត់ ជនជាប់ចោទបានលើកឡើងថា ខ្សែភាពយន្តឯកសារនេះមិនមាននូវយថាភាព ដោយផ្តល់នូវឧទាហរណ៍មួយចំនួនសម្រាប់ការលើកឡើងនេះក្នុងអំឡុងពេលសវនាការបឋម ។ ជនជាប់ចោទគួរតែបង្ហាញនូវទឡ្ហីករណ៍របស់គាត់ជាលាយលក្ខណ៍អក្សរ ដែលទឡ្ហីករណ៍នេះត្រូវដាក់ត្រឹមថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩។

១៤. សហព្រះរាជអាជ្ញា និងភាគីដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈមេធាវីរបស់ខ្លួន នឹងមានពេលវេលាពីរសប្តាហ៍ ដើម្បីធ្វើការឆ្លើយតប។

១៥. អង្គជំនុំជម្រះយល់ឃើញថា ខ្សែភាពយន្តឯកសារទាំងពីរភាគនេះអាចទទួលយកបាន តែជាកម្មវត្ថុនៃការពិនិត្យឡើងវិញលើភាពពាក់ព័ន្ធក្នុងអំឡុងពេលសវនាការលើអង្គសេចក្តី ។

**សេចក្តីសម្រេច និងសេចក្តីណែនាំ**

E5/10/2

**ផ្អែកតាមសំអាងហេតុខាងលើ:**

១៦. អង្គជំនុំជម្រះសូមធ្វើការណែនាំ និងសម្រេចដូចខាងក្រោម :

១. ឯកសារដែលមានចំណងជើង "ផែនការរួមចុងក្រោយ" ត្រូវបានប្រកាសថាអាចទទួលយកបាន។

២. សហព្រះរាជអាជ្ញាត្រូវបានណែនាំឱ្យធ្វើសំណើជាផ្លូវការសុំភស្តុតាងពីសារៈមន្ទីរទួលស្លែង និង/ឬ ពីសាកលវិទ្យាល័យCornell ដើម្បីបង្ហាញថាភាពត្រឹមត្រូវ នូវឯកសារដែលមានចំណងជើងថា "ផែនការរួមចុងក្រោយ" ដែលសហព្រះរាជអាជ្ញាបានដាក់ ហើយសហព្រះរាជអាជ្ញាមានពេលវេលារហូតដល់ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០០៩ ដើម្បីអនុវត្តតាមការណែនាំនេះ។

៣. សេចក្តីណែនាំបន្ថែមនឹងផ្តល់ជូន បន្ទាប់ពីទទួលបានភស្តុតាងពីស្ថាប័នណាមួយ ឬបន្ទាប់ពីបានទទួលរបាយការណ៍ពីសហព្រះរាជអាជ្ញា ដែលស្នើសុំឱ្យមានការណែនាំបន្ថែមទៀត ឬការណែនាំណាមួយផ្សេងទៀត ។ ជនជាប់ចោទក៏ទទួលបានសិទ្ធិក្នុងការឆ្លើយតបក្នុងរយៈពេលណាមួយសមស្រប ។

៤. ខ្សែភាពយន្តឯកសារទាំងពីរភាគនេះ ប្រកាសថាអាចទទួលយកបាន តែជាកម្មវត្ថុនៃការពិនិត្យឡើងវិញលើភាពពាក់ព័ន្ធ និងយថាភាពរបស់វាក្នុងពេលសវនាការលើអង្គសេចក្តី ។

៥. មេធាវីការពារក្តីមានពេលវេលារហូតដល់ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩ ដើម្បីដាក់សេចក្តីសន្និដ្ឋានដោយសង្ខេប ដែលបង្ហាញនូវមូលហេតុក្នុងការពិនិត្យឡើងវិញនូវសុពលភាពនៃខ្សែភាពយន្តនោះ ដោយផ្តោតទៅលើភាគទាំងពីរដែលសហព្រះរាជអាជ្ញាមានបំណងដាក់ជូន ។

៦. សហព្រះរាជអាជ្ញា និងភាគីដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈមេធាវីរបស់ខ្លួន នឹងមានពេលវេលាពីរសប្តាហ៍ដើម្បីធ្វើការឆ្លើយតប។ NWN

ភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C E T C

**និល ណុន**